ផ្សារមូលបត្រកម្ពុជា
CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខ: ......០៣៤/១៣....

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្ដីជូនដំណឹង
## ស្ដីពីការកែប្រែប្រតិបត្តិការទីផ្សារមូលបត្រ

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (**ផ.ម.ក.**) មានកិត្តិយសសូមជម្រាបជូនសាធារណៈជនមេត្តាជ្រាបថា ចាប់ពី **ថ្ងៃទី ១១ ខែមិនា ឆ្នាំ២០១៣** នេះតទៅ **ផ.ម.ក.** នឹងធ្វើការបង្កើនចំនួនដងនៃការអនុវត្តការផ្គូផ្គងមូលបត្រ និងកែប្រែឯកតាគម្លាតថ្លៃ ស្របតាមវិសោធនកម្មនៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ អនុម័តដោយគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) តាមរយៈ ប្រកាសលេខ ០០១/១៣ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការដាក់ឲ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**១.ចំនួនដងនៃការអនុវត្តការផ្គូផ្គង៖** កើនពី ០២ ដង ក្នុងមួយថ្ងៃ ទៅ ០៦ ដង ក្នុងមួយថ្ងៃ (ប្រការ ៦ ថ្មី)

**ម៉ោងអនុវត្តការផ្គូផ្គងបច្ចុប្បន្ន**




**ម៉ោងអនុវត្តការផ្គូផ្គងថ្មី**




**២.ការកែប្រែឯកតាគម្លាតថ្លៃ (ប្រការ ១០ ថ្មី)៖**

**គម្លាតថ្លៃបច្ចុប្បន្ន**

| លរ | ថ្លៃមូលបត្រ (រៀល) | គម្លាតថ្លៃ (រៀល) |
|---|---|---|
| ១ | ]០–៥០.០០០[ | ៥០ |
| ២ | [៥០.០០០–៥០០.០០០[ | ២៥០ |
| ៣ | [៥០០.០០០–[ | ៥០០ |

**គម្លាតថ្លៃថ្មី**

| លរ | ថ្លៃមូលបត្រ (រៀល) | គម្លាតថ្លៃ (រៀល) |
|---|---|---|
| ១ | ]០–៤.០០០[ | ១០ |
| ២ | [៤.០០០–២០.០០០[ | ២០ |
| ៣ | [២០.០០០–៤០.០០០[ | ៥០ |
| ៤ | [៤០.០០០–១០០,០០០[ | ១០០ |
| ៥ | [១០០.០០០–២០០.០០០[ | ២០០ |
| ៦ | [២០០.០០០–៤០០.០០០[ | ៥០០ |
| ៧ | [៤០០.០០០–[ | ១.០០០ |

៣. សម្រាប់វិសោធនកម្មដទៃទៀត សូមពិនិត្យមើលក្នុងប្រកាសស្ដីពីការដាក់ឲ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នៅក្នុងគេហទំព័ររបស់ **គ.ម.ក.** ឬ **ផ.ម.ក.**។

សម្រាប់ព័ត៌មានបន្ថែម ឬសំនួរពាក់ព័ន្ធនឹងការកែប្រែប្រតិបត្តិការទាំងនេះ សូមទាក់ទងមក **ក. គីម សុផានីតា** តាមរយៈសារអេឡិចត្រូនិក sophanita.kim@csx.com.kh ឬទូរសព្ទលេខ (+៨៥៥) ១២ ២៥១ ២៣១។

ភ្នំពេញ ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៣
ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)